# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីន័យនាមបញ្ញត្តិរបស់អ្នកកាន់ព្រះពុទ្ធសាសនា

web site: wwww.hoksavann.org

ថ្ងៃទី១៧ កញ្ញា ២០០៥

អ្នកកាន់ព្រះពុទ្ធសាសនាបានអនុវត្តតាមធម៌ព្រះពុទ្ធមានប្រភេទផ្សេងគ្នា គេឲ្យឈ្មោះទៅតាមការអនុវត្តន៍ដូចតទៅនេះ ៖

១- ពាក្យថា ពុទ្ធមាមិកជនប្រែថា អ្នករាប់អានព្រះពុទ្ធឬរាប់អានព្រះពុទ្ធសាស-នា គឺអ្នកដែលយល់ថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ជាពាក្យប្រៀនប្រដៅត្រឹមត្រូវ មានសច្ចភាព ជាពាក្យដឹកនាំមនុស្សសត្វឲ្យចេញចាកទុក្ខ ក៏ស្រឡាញ់ចូលចិត្តពោលសរសើរ គាំទ្រនូវពាក្យប្រៀនប្រដៅនោះ ហើយប្រតិបត្តិតាមធម៌ព្រះពុទ្ធផ្នែកណាមួយ ។

២- ពាក្យថា ទាយក ប្រែថា អ្នកឲ្យទានភេទបុរស ទាយិកា អ្នកឲ្យទានភេទស្ត្រី បានដល់បុរសស្ត្រីណា បានជួយសង្គ្រោះអ្នកដទៃ ដោយកម្លាំងកាយ កម្លាំងទ្រព្យសម្បត្តិ កម្លាំងគំនិតប្រាជ្ញា ដូចបាយទឹកនំចំណីដល់មាតាបិតា បូជាព្រះសង្ឃដោយបច្ច័យ៤ លោកហៅថាទាយក ទាយិកា ។

៣- ពាក្យថាឧបាសក ឧបាសិកា ប្រែថា បុរសស្ត្រីណាដែលចូលទៅអង្គុយគិតព្រះរតនត្រ័យ ។ ពាក្យថាចូលទៅអង្គុយជិត ពុំមែនចូលទៅអង្គុយជិតដោយរូបកា-យទេ គឺចូលទៅអង្គុយជិតដោយខ្សែគំនិត គឺជឿគុណព្រះរតនត្រ័យ ។ បានសេចក្តីថា ជឿព្រះពុទ្ធជាអ្នកត្រាស់ដឹងនូវធម៌ ជឿព្រះធម៌ដឹកនាំសត្វឲ្យចាកចេញទុក្ខ ជឿព្រះសង្ឃជាអ្នកប្រតិបត្តិតាមសីលធម៌សមាធិបញ្ញា ដើម្បីរំលត់ទុក្ខពិតមែន ជាពិសេសជឿកម្មនិងផលរបស់កម្ម ហើយប្រតិបត្តិតាមមានរក្សាសីលជាដើម ហៅថាឧបាសក ឧបាសិកា ។

៤- ពាក្យថា ពុទ្ធសាសនិកជន ប្រែថាជនជាអ្នកពុទ្ធសាសនា គឺជាអ្នកអនុវត្តតាមធម៌របស់ព្រះពុទ្ធសាសនា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធយ៉ាងណាក៏ប្រតិបត្តិតា

មយ៉ាងនោះ គឺមានចរិតលក្ខណៈជាអ្នកពុទ្ធសាសនា ហៅថាពុទ្ធសាសនិកជន ។ ពាក្យនេះ ហៅបានទាំងព្រះសង្ឃទាំងគ្រហស្ថ ។

៥- ពាក្យថា ពុទ្ធបរិស័ទ ប្រែថាការអង្គុយជុំវិញព្រះពុទ្ធ ។ បានសេចក្តីថា អ្នកអនុវត្តតាមឱវាទរបស់ព្រះពុទ្ធ ហើយរក្សាការពារនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធមិនឲ្យបាត់បង់ ។ បើមានគេសង្ស័យអំពីធម៌វិន័យរបស់ព្រះពុទ្ធតែងតែព្យាយាមដោះស្រាយតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គបង្ហាសេចក្តីពិត ដើម្បីកំចាត់បង់នូវសេចក្តីសង្ស័យនោះ ។ ពាក្យថា អង្គុយជុំវិញបានសេចក្តីថា មានខ្សែគំនិតជុំវិញធម៌វិន័យរបស់ព្រះពុទ្ធ។ ពាក្យថាពុទ្ធបរិស័ទបានទាំងបុព្វជិតបរិស័ទទាំងគ្រហស្ថបរិស័ទ។

៦- ពាក្យថា ពុទ្ធសាវក ប្រែថា សាវករបស់ព្រះពុទ្ធ ។ សាវកនេះ លោកច្រើននិយាយសំដៅទៅលើព្រះអរហន្តដូចជាអគ្គសាវកទាំងពីរ គឺព្រះសារីបុត្តជាសាវកស្តាំ និងព្រះមោគ្គល្លានជាសាវកឆ្វេងរបស់ព្រះពុទ្ធ ឬសាវកទាំង៨០ ហៅថាអសីតិមហាសាវកជាដើម ។ សាវកនេះ ជាជំនួយយ៉ាងសំខាន់ណាស់ដល់ព្រះអង្គក្នុងការជួយផ្សាយព្រះពុទ្ធសាសនា ។

ដើម្បីឲ្យព្រះពុទ្ធសាសនាស្ថិតនៅនិងលូតលាស់ចំរើន ព្រះពុទ្ធសំដែងថា ដោយសារពុទ្ធបរិស័ទរបស់ព្រះអង្គទាំង៤ពួក គឺភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកាប្រតិបត្តិតាមហេតុ៥ប្រការដូចតទៅនេះ ៖

១- ស្តាប់ធម៌ដោយគោរព គឺព្យាយាមស្តាប់ទេសនា ស្តាប់ឱវាទ ស្តាប់ធម្មកថាដែលនិយាយពន្យល់អំពីធម៌វិន័យរបស់ព្រះពុទ្ធ ។ ក្រៅពីនោះ ឧស្សាហ៍ធ្វើធម្មសាកច្ឆា ធ្វើការសន្ទនាធម៌ ដើម្បីកំចាត់ការសង្ស័យក្នុងធម៌វិន័យរបស់ព្រះពុទ្ធ ។

២- រៀនធម៌ដោយគោរព គឺយកចិត្តទុកដាក់សិក្សារៀនសូត្រធម៌វិន័យរបស់ព្រះពុទ្ធ ឲ្យយល់ច្បាស់ ដោយលើកយកគោលធំៗរបស់ព្រះអង្គមកសិក្សាជាមួយលោកអ្នកចេះដឹងព្រះពុទ្ធសាសនា ។ ជាមួយគ្នានោះ ត្រូវខំស្រាវជ្រាវមើលគម្ពីរក្បួនច្បាប់ព្រះពុទ្ធសាសនាឲ្យបានច្រើនថែមទៀត ។

៣- ទ្រទ្រង់ធម៌ដោយគោរព គឺចងចាំនូវធម៌ដែលបានស្តាប់បាន រៀនហើយឲ្យជក់ជាប់នៅក្នុងចិត្ត ដែលក្នុងបាលីពោលថា យោនិសោមនសិការៈ ប្រែថាធ្វើទុកក្នុងចិត្តនូវធម៌ដោយឧបាយនៃបញ្ញា ។

៤- ពិចារណានូវធម៌ដោយគោរព គឺពិចារណាឲ្យយល់នូវអត្ថន័យនិងអត្ថរសនៃព្រះធម៌ឲ្យបានច្បាស់លាស់ ។

៥- ប្រតិបត្តិតាមធម៌ដោយគោរព គឺប្រតិបត្តិធម៌ដែលបានយល់ច្បាស់ហើយដោយយកចិត្តទុកដាក់ រហូតឃើញច្បាស់ក្នុងចិត្តរបស់ខ្លួន ក្នុងបាលីថា សន្ទិដ្ឋិកោ ប្រែថា ដឹងពិតឃើញពិតនិងពាក្យថា បច្ចត្តំ វេទិតព្វោ ប្រែថាឃើញច្បាស់ក្នុងចិត្តនៃខ្លួន គឺឃើញនូវខន្ធ៥ មានរូបខន្ធជាដើម ប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ និងអនត្តា ។៚